ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១២៩ ប្រក កសក

# ប្រកាស
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ
# ចំណុះនាយកដ្ឋានពូជដំណាំនៃអគ្គនាយកដ្ឋានកសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា២៧ និងមាត្រា៣៤នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់



64

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

ស្នើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃ ទី២៦ ខែកក្កដា ឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យ១៦៣ អនក្រ.បក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានពូជដំណាំចំណុះអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ១០៩ ប្រក.កសក.ប ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងអង្គភាពចំណុះនាយកដ្ឋាន និងមន្ទីរពិសោធន៍ជាតិកសិកម្មក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម
- យោងលិខិតលេខ២១៩៣ មស.នក ចុះថ្ងៃអង្គារ ១១រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

**ប្រការ១.-**

នាយកដ្ឋានពូជដំណាំនៃអគ្គនាយកដ្ឋានកសិកម្ម មានការិយាល័យចំណុះចំនួន៣(បី)ដូចមានខាងក្រោម ៖

- ការិយាល័យរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ
- ការិយាល័យចុះបញ្ជីប្រភេទពូជដំណាំ និងបញ្ជាក់គុណភាពពូជដំណាំ
- ការិយាល័យនីតិកម្ម និងអធិការកិច្ចពូជដំណាំ។

អង្គការលេខរបស់នាយកដ្ឋានពូជដំណាំនៃអគ្គនាយកដ្ឋានកសិកម្ម មានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២.-**

ការិយាល័យនីមួយៗមានភារកិច្ចដូចខាងក្រោម ៖

**២.១. ការិយាល័យរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ**

- រៀបចំគោលនយោបាយ កសាងផែនការយុទ្ធសាស្ត្រ ផែនការថវិកាកម្មវិធី និងគម្រោងអភិវឌ្ឍពូជដំណាំ ក្នុងគោលដៅលើកកម្ពស់គុណភាព និងការផ្គត់ផ្គង់ពូជដំណាំប្រកបដោយប្រសិទ្ធភាពខ្ពស់
- ចូលរួមអនុវត្តអនុសញ្ញាកិច្ចព្រមព្រៀងនិងកិច្ចសហប្រតិបត្តិការទាក់ទងនឹងការគ្រប់គ្រងពូជដំណាំនៅថ្នាក់ជាតិ និងអន្តរជាតិ
- ធ្វើការទំនាក់ទំនង សម្របសម្រួល ផ្លាស់ប្តូរព័ត៌មាន សហការជាមួយអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងដៃគូអភិវឌ្ឍនានា
- គ្រប់គ្រងធនធានមនុស្ស ការងាររដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ បទបញ្ជាផ្ទៃក្នុង និងការងារពិធីការផ្សេងៗ
- គ្រប់គ្រង ចរាចរ និងតម្កល់រាល់ឯកសារកិច្ចការរដ្ឋបាល
- គ្រប់គ្រង និងដំណើរការកិច្ចការគណនេយ្យ ហិរញ្ញវត្ថុ និងបញ្ជីសារពើភ័ណ្ឌ
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំស្តីពីសកម្មភាព និងលទ្ធផលការងារ

- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

**២.២. ការិយាល័យចុះបញ្ជីប្រភេទពូជដំណាំ និងបញ្ជាក់គុណភាពពូជដំណាំ**

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យ
- រៀបចំបែបបទ និងនីតិវិធីចុះបញ្ជីប្រភេទពូជដំណាំ ផ្តល់ព័ត៌មានដល់អតិថិជន និងផ្តល់ការគាំទ្របច្ចេកទេសដល់អ្នកពាក់ព័ន្ធនានា
- រៀបចំស្តង់ដាពូជដំណាំទៅតាមប្រភេទនីមួយៗ ដែលអនុញ្ញាតឱ្យប្រើប្រាស់
- រៀបចំបញ្ជីប្រភេទពូជដំណាំរបស់ជាតិ ចរិតលក្ខណប្រភេទពូជដំណាំ បញ្ជីប្រភេទពូជដំណាំដែលបញ្ចេញឱ្យប្រើប្រាស់ និងប្រភេទពូជថ្មីនៃដំណាំ
- ផ្តល់ការបណ្តុះបណ្តាលស្តីពីនីតិវិធីចុះបញ្ជីប្រភេទពូជដំណាំ និងការបញ្ជាក់គុណភាពពូជដំណាំ
- ធ្វើពិសោធន៍វាយតម្លៃ លក្ខណខុសប្លែក ឯកសណ្ឋានភាព និងស្ថេរភាពនៃប្រភេទពូជថ្មីសម្រាប់ចុះបញ្ជី និងស្នើសុំការពារសិទ្ធិជាម្ចាស់ប្រភេទពូជថ្មីនៃដំណាំ
- ធ្វើពិសោធន៍វាយតម្លៃប្រភេទពូជដំណាំ និងកំណត់ប្រភេទពូជដំណាំដែលបង្កគ្រោះថ្នាក់
- រៀបចំទម្រង់ការ និងលក្ខណនៃស្លាកសញ្ញាព័ត៌មានអំពីពូជដំណាំគ្រប់ប្រភេទជាភាសាខ្មែរ
- វាយតម្លៃភាពសុទ្ធ អត្រាដំណុះ អត្រាសំណើម និងសុខភាពពូជដំណាំ
- ត្រួតពិនិត្យ វាយតម្លៃផលិតកម្មពូជដំណាំ ដើម្បីចេញវិញ្ញាបនប័ត្របញ្ជាក់គុណភាពពូជដំណាំ
- ផ្តល់ការណែនាំស្តីពីការធ្វើអាជីវកម្មពូជដំណាំ និងការគ្រប់គ្រងសន្និធិពូជដំណាំ
- គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃគុណភាពពូជដំណាំទៅតាមស្តង់ដាពូជដំណាំ
- រៀបចំចងក្រង រក្សាព័ត៌មាន និងស្ថិតិស្តីពីផលិតកម្ម ការធ្វើអាជីវកម្ម ការនាំចូល នាំចេញ ចែកចាយ និងសន្និធិពូជដំណាំ
- រៀបចំបង្កើតប្រព័ន្ធទិន្នន័យគ្រឹះសម្រាប់គ្រប់គ្រងទិន្នន័យបញ្ជាក់គុណភាពពូជដំណាំ
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំស្តីពីសកម្មភាព និងលទ្ធផលការងារ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។

**២.៣. ការិយាល័យនីតិកម្ម និងអធិការកិច្ចពូជដំណាំ**

- រៀបចំផែនការសកម្មភាពការងាររបស់ការិយាល័យ
- រៀបចំបទដ្ឋានគតិយុត្តដែលស្ថិតនៅក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំនានា ដើម្បីជំរុញការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព
- ផ្តល់ការបណ្តុះបណ្តាលស្តីពីនីតិវិធីនៃការត្រួតពិនិត្យ គោលការណ៍ណែនាំនានា ការវាយតម្លៃគុណភាពពូជដំណាំ និងនីតិវិធីអនុវត្តច្បាប់
- តាមដានការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ដែលស្ថិតនៅក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- ធ្វើអធិការកិច្ចរាល់សកម្មភាពពាក់ព័ន្ធពូជដំណាំ ទប់ស្កាត់បទល្មើស ទទួលពាក្យបណ្តឹង កសាងសំណុំរឿងនៃបទល្មើស និងដោះស្រាយបទល្មើសតាមនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន
- ផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- សរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំស្តីពីសកម្មភាព និងលទ្ធផលការងារ
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន។



44

**ប្រការ៣.-**

ការិយាល័យនីមួយៗដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការអនុលោមតាមបទប្បញ្ញត្តិដែលមានជាធរមាន។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានអង្គភាពដែលពាក់ព័ន្ធ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច ១៤រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ឧបសម្ព័ន្ធនៃប្រកាសលេខ.....១២៩ ប្រក.កសក...ចុះថ្ងៃ.ព្រហ.៣រោច.ខែ.ផល្គុន.....ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ត្រូវនឹង ថ្ងៃទី...១២.....ខែ......មីនា.....ឆ្នាំ២០២០

## អង្គការលេខរបស់នាយកដ្ឋានពូជដំណាំ

**ថ្នាក់ដឹកនាំនាយកដ្ឋានពូជដំណាំ**

- ការិយាល័យរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ
- ការិយាល័យចុះបញ្ជីប្រភេទពូជដំណាំ និងបញ្ជាក់គុណភាពពូជដំណាំ
- ការិយាល័យនីតិកម្ម និងអធិការកិច្ចពូជដំណាំ